# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHRC)
# បណ្តឹងលេខ១៤២១/២០០៥

**១.ពាក្យគន្លឹះ៖** ទោសប្រហារជីវិត, សន្មត់ថាមិនទាន់មានទោស, សមភាពរវាងភាគី, ការត្រួតពិនិត្យដោយតុលាការជាន់ខ្ពស់, វិនិច្ឆ័យសេចក្តីដោយមិនលម្អៀង, សវនាការក្នុងរយៈពេលសមស្រប

**២. នីតិវិធី៖** ក្នុងឆ្នាំ១៩៩៩ និង ២០០៤ ជនជាប់ចោទ (Francisco) ជាអ្នកប្តឹង និងបុគ្គលមួយចំនួនទៀត ត្រូវបានឃាត់ខ្លួន និងឃុំពីបទចាប់ជម្រិត រំលោភ និងសម្លាប់។ គាត់ បានព្យាយាមតវ៉ា កុំឲ្យមានការចោទប្រកាន់ និងឃាត់ខ្លួន។ ទោះបីជាយ៉ាងណា តុលាការបដិសេធ និងនាំឲ្យមានការចាប់ និងសវនាការ។ ជនជាប់ចោទ មានមេធាវី តែត្រូវបានដក និងជាប់ទោសពីបទប្រមាថតុលាការ (contempt of court)។ មេធាវី ត្រូវបានតែងតាំងដោយតុលាការ តែមិនមានពេលពិនិត្យសំណុំរឿងទេ ដោយសារចៅក្រមមិនអនុញ្ញាតឲ្យមានការពន្យា ទោះបីមានការស្នើសុំក្តី។ មេធាវី ដែលជនជាប់ចោទជួល មិនត្រូវបានទទួលស្គាល់។

ក្នុងពេលសវនាការ សហជនជាប់ចោទ ត្រូវបានលើកទឹកចិត្តឲ្យឆ្លើយសារភាព ជាមួយការសន្យាថាមិនចោទប្រកាន់។ សាក្សីជាច្រើនរបស់រដ្ឋអាជ្ញា ត្រូវបានស្តាប់ចម្លើយ ក៏ប៉ុន្តែ សាក្សីរបស់ជនជាប់ចោទ ត្រូវបានកម្រិត ដោយសារថាមិនពាក់ព័ន្ធ។

ចៅក្រមជាន់ទាប បានសម្រេចថា មិនមានភស្តុតាងគ្រប់គ្រាន់ មានទោសបទជម្រិត តែចៅក្រមកំពូល រកឃើញថាមានទោស ក្នុងបទផ្សេង និងដាក់ទោសប្រហារជីវិត។ ចៅក្រម សម្រេចទោសផ្អែកលើសាក្សី ជាសហជនជាប់ចោទ (ភូតកុហក) និង ភស្តុតាងដែលមិនគ្រប់គ្រាន់ ព្រមទាំងដាក់បន្ទុកឲ្យជនជាប់ចោទបង្ហាញថាគាត់មិននៅកន្លែងកើតហេតុ។ បន្ថែមពីលើនេះ ក្នុងដំណើរសវនាការ ប្រព័ន្ធផ្សព្វផ្សាយ ផ្សាយអវិជ្ជមាន មុនចេញសាលក្រម ដែលជាការដាក់សំពាធលើតុលាការ។ ផ្អែកតាមអង្គហេតុទាំងអស់ខាងលើ ជនជាប់ចោទ (អ្នកប្តឹង) ថ្លែងថា រដ្ឋភាគី (ប្រទេសហ្វីលីពីន) បានបំពានមាត្រា៦, ៧,៩ និង១៤ នៃកតិកាសញ្ញា។

រដ្ឋភាគី បានអះអាងបដិសេធការចោទប្រកាន់ ដោយក្នុងនោះអះអាងថា ជនជាប់ចោទ មានបន្ទុកភស្តុតាងក្នុងការបង្ហាញ *alibi* (កថាខ័ណ្ឌទី៤.៦)។ បន្ថែមពីលើនេះ តុលាការកំពូល មិនទទួលរងសំពាធទេ ក្នុងការចេញសេចក្តីសម្រេច ដោយសារតុលាការសម្រេចទាំងអស់រួមគ្នា (កថា.៤.៧)។ រដ្ឋភាគី ក៏បាន

អះអាងតបថា សាក្សីរបស់ជនជាប់ចោទ មិនត្រូវបានរារាំងឲ្យធ្វើសក្ខីកម្មទេ តែដោយសារមានសក្ខីកម្មស្រដៀងគ្នារួចហើយ (កថា ៤.៨ និង ៤.៩)។

## ៣. សំអាងហេតុ និងសេចក្តីសម្រេច

**ក**. ដោយសារការសម្រេចផ្តន្ទាទោសប្រហារជីវិតជាស្វ័យប្រវត្តិ ដោយគ្មានពិចារណានូវស្ថានភាពបុគ្គល ឬស្ថានភាពនៃបទល្មើស គណៈកម្មាធិការ រកឃើញថារដ្ឋជាភាគី បានបំពានមាត្រា៦។

**ខ**. ពាក់ព័ន្ធមាត្រា ១៤(២) (សន្មត់ថាមិនទាន់មានទោស) គណៈកម្មាធិការ យល់ថាមានការលម្អៀងលើសាក្សី ដោយឲ្យសាក្សីខាងចោទប្រកាន់ អាចត្រូវបានសួរដេញដោល ខណៈសាក្សីខាងជនជាប់ចោទ ត្រូវបានកម្រិតមិនឲ្យសួរដេញដោលទូលំទូលាយ។ ជាពិសេស សាក្សីដែលគាំទ្រថា ជនជាប់ចោទមិននៅកន្លែងកើតហេតុ នាពេលបទល្មើស ត្រូវបានប្រព្រឹត្ត (*alibi*) បន្ថែមពីលើនេះ មានការគម្រាមដល់ចៅក្រម ថាត្រូវសម្រេចទោសប្រហារជីវិត ទោះបីដំណើរការសវនាការ មិនទាន់បានបញ្ចប់ក្តី។ នេះបង្ហាញពីការបំពានមាត្រា ១៤(២)។

**គ**. ទាក់ទងនឹងសិទ្ធិទទួលបានមេធាវី មេធាវីដែលត្រូវបានតែងតាំង មិនត្រូវបានផ្តល់ឲ្យទាន់ពេលទេ ហើយក៏មិនបានពន្យាពេលតាមសំណើមេធាវី ដើម្បីបានសិក្សាសំណុំរឿងមុននឹងចូលរួមការពារក្តី (មួយថ្ងៃមុនសវនាការ)។ បន្ថែមពីលើនេះ ទោះបីជាជនជាប់ចោទ មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង ក៏ប៉ុន្តែតុលាការបានបដិសេធ ដែលនេះជាការបដិសេធនូវតំណាងការពារមានប្រសិទ្ធភាព ដែលខុសនឹងមាត្រា ១៤(៣ខ និង ឃ)។

**ឃ**. សាក្សីរបស់រដ្ឋអាជ្ញា ត្រូវបានអនុញ្ញាតឲ្យធ្វើសក្ខីកម្ម ក៏ប៉ុន្តែតុលាការបដិសេធ មិនឲ្យសាក្សីរបស់ជនជាប់ចោទធ្វើ ដោយអះអាងថា ភស្តុតាងមិនពាក់ព័ន្ធ និងមិនគាំទ្រ។ ការអះអាងនេះ ក្នុងរឿងចោទប្រកាន់ធ្ងន់ធ្ងរ (ទោសប្រហារជីវិត) មិនគ្រប់គ្រាន់ទេ។ ដូចនេះវាបំពានគោលការណ៍សមភាពនៃភាគីចែងក្នុងមាត្រា ១៤(៣ង)។

**ង**. ក្នុងរឿងនេះ តុលាការកំពូល បានសម្រេចដាក់ទោសប្រហារជីវិត បទល្មើសដែលតុលាការជាន់ទាបសម្រេចឲ្យរួចខ្លួន ហើយរដ្ឋអាជ្ញាមិនទាមទារឲ្យកែប្រែទោសទេ។ នីតិវិធីរបស់តុលាការកំពូល ផ្តោតលើទាំងអង្គហេតុ និង អង្គច្បាប់ ក៏ប៉ុន្តែ បានសម្រេចដោយគ្មានស្តាប់សក្ខីកម្ម។ តាមខ្លឹមសារមាត្រា ១៤ នៃកតិកា តុលាការកំពូល ត្រូវគោរពតាមគោលការណ៍ជំនុំជម្រះសេចក្តីក្នុងនីតិវិធីប្រភេទនេះ។ ដោយសារតុលាការកំពូល សម្រេចទោសប្រហារជីវិតជាលើកទី១ និងចុងក្រោយ ដែលបិទផ្លូវតវ៉ា វាបំពានមាត្រា ១៤(កថាខ័ណ្ឌទី១ និង២) ដោយសារជនជាប់ចោទ មិនមានលទ្ធភាពតវ៉ា។

**ច.** ក្នុងដំណើរការក្តី ចៅក្រមជំនុំជម្រះម្នាក់ និងចៅក្រមតុលាការកំពូលចំនួន ២រូប បានចូលរួមក្នុងនីតិវិធីវាយតម្លៃចោទប្រកាន់ជាបឋម ហើយក្រោយមក ចូលរួមសម្រេចសេចក្តីក្នុងរឿងនេះ ដែលនេះនាំមិនមែនជាសវនាការមិនលម្អៀងទេ។ វានាំឲ្យខុសមាត្រា ១៤(១)។

**ឆ.** ចាប់តាំងពីការឃាត់ខ្លួន មកដល់សាលដីកាតុលាការកំពូល មានរយៈពេល ជិត៨ឆ្នាំ។ ការយឺតយ៉ាវនេះ មិនបង្កដោយជនជាប់ចោទទេ តែដោយអាជ្ញាធរ (បំពានមាត្រា ១៤(៣.គ)។

**ជ.** ការសម្រេចទោសប្រហារជីវិត ក្រោយពីមានសវនាការមិនយុត្តិធម៌ ធ្វើឲ្យជនជាប់ចោទភ័យ និងលទ្ធភាពនៃការប្រហារជីវិតនឹងកើតមាន ដែលវាបង្កើតជាសំពាធផ្លូវចិត្ត។ នេះនាំឲ្យបំពានមាត្រា៧នៃកតិកាសញ្ញា។

## ៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)

*តុលាការព្រហ្មទណ្ឌ អាចដាក់ទោសបុគ្គលណាមួយ នៅពេលមិនមានមន្ទិលសមហេតុផលនៃពិរុទ្ធភាពរបស់គាត់ ហើយវាជាការងាររបស់រដ្ឋអាជ្ញា ក្នុងការជម្រះមន្ទិលទាំងនោះ។ ក្នុងសំណុំរឿងនេះ ចៅក្រមជំនុំជម្រះ បានសួរសំណួរនាំមុខមួយចំនួនដល់ភាគីចោទប្រកាន់ ដែលទំនងជាធ្វើយុត្តិកម្មលើសេចក្តីសន្និដ្ឋានថា អ្នកប្តឹង* (ជនជាប់ចោទ) *មានពិរុទ្ធភាព មុនពេលពិរុទ្ធភាព ត្រូវបានបង្ហាញ។ បន្ថែមពីលើនេះ តាមយោបល់របស់គណៈកម្មាធិការ ភស្តុតាងដាក់បន្ទុកផ្តល់ដោយជនសមគំនិត ដែលត្រូវបានចោទលើបទឧក្រិដ្ឋដូចគ្នា គួរតែត្រូវបានពិចារណាឲ្យហ្មត់ចត់ ជាពិសេសនៅពេលដែល ជនសមគំនិតនោះ កុហកអំពីពិរុទ្ធភាពមុនរបស់គាត់ ហើយដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិរួចពីការចោទប្រកាន់ ហើយក្រោយមកទទួលថាគាត់បានរំលោភសេពសន្ថវៈជនរងគ្រោះម្នាក់ដែរ* (កថាខ័ណ្ឌទី៧.៤)។

គណៈកម្មាធិការ យោងដល់យោបល់ទូទៅលេខ១៣ ស្តីពីមាត្រា១៤ របស់ខ្លួនថា៖ *ដូចនេះ វាជាកាតព្វកិច្ចរបស់មន្ត្រីសាធារណៈទាំងអស់ ក្នុងការមិនធ្វើបុរេវិនិច្ឆ័យជាមុនអំពីលទ្ធផលនៃសវនាការ* (កថាខ័ណ្ឌទី៧.៤)។

ទស្សនៈទាំងស្រុងសូមមើល៖ CCPR/C/87/D/1421/2005, Francisco v. the Philippines